# មេរៀនទី ៦៨៖ ហេតុអ្វីបានជាព្រះវរបិតាបញ្ជូនព្រះយេស៊ូវមក

## យ៉ូហាន ៣៖១២-២១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/QTjdEpWzddE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/LYR_qC--Hr8

**គោលបំណង៖** ព្រះយេស៊ូវមកដើម្បីជួយសង្គ្រោះពួកយើង

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣៖១៧** *"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0
២. ទ្រង់យាងមកផ្តល់ជីវិត https://youtu.be/PXQCMUWh9RY
៣. ខ្ញុំសូមលើកព្រះនាមទ្រង់ឡើង https://youtu.be/rPE5QOHbo70

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ទូកលិច»

សម្ភារៈដែលត្រូវការ៖ ក្រដាសធំ៣ផ្ទាំង អាស្រ័យទៅតាមចំនួនកុមារ



១. ដាក់ក្រដាសធំទាំង៣ផ្ទាំងនោះ នៅចំកណ្តាលថ្នាក់រៀន

២. នៅពេលដែលគ្រូស្រែក "ទូកលិចហើយ!" ដូច្នេះកុមារទាំងអស់ ត្រូវលោតឡើងលើក្រដាស ដើម្បីទទួលបានការសង្គ្រោះ។

៣. បត់ក្រដាសនោះឲ្យតូច ហើយលេងល្បែងនោះម្តងទៀត។ បន្តលេងល្បែងនេះរហូតដល់ក្រដាសនោះ នៅសល់តូចបំផុត។

៤. ក្រដាសតំណាងឱ្យទូកសង្គ្រោះ ហើយប្រសិនបើយើងមិនលោតឡើងលើក្រដាសនោះ យើងនឹងមិនត្រូវបានសង្គ្រោះទេ។

៥. ព្រះបានចាត់ព្រះរាជបុត្រារបស់ព្រះអង្គមកសង្គ្រោះយើងពី អំពើបាបរបស់យើងដូចជាទូកសង្គ្រោះអីចឹង។

### ៤. ការណែនាំមេរៀន

តើអ្នកមាននរណាម្នាក់ដែលអ្នកអាចស្លាប់ជំនួសគេបានដែរឬទេ? បើមិត្តភក្តិអ្នកលង់ទឹកទន្លេ តើអ្នកលោតទៅជួយគេដែរឬទេ? ចុះបើអ្នកដឹងថាអ្នកនឹងស្លាប់នៅពេលដែលអ្នកជួយមិត្តរបស់អ្នករួច? ហើយចុះ បើសិនជាមិត្តភក្តិមិនដែលស្តាប់ឬស្រលាញ់អ្នកនោះ? តើអ្នកនៅតែលោតចូលដើម្បីជួយសង្គ្រោះគេដែរទេ? ថ្ងៃនេះ យើងនឹងរៀនអំពីព្រះយេស៊ូវ ដែលបានសុគតសម្រាប់មនុស្សគ្រប់គ្នា បើទោះបីជាអ្នកមិនដែលបានស្តាប់តាមទ្រង់ ឬស្រឡាញ់ទ្រង់ក៏ដោយ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពី ២០០០ឆ្នាំមុនព្រះយេស៊ូវបានយាងមក ហើយមនុស្សមានការយល់ច្រឡំពីការយាងមករបស់ទ្រង់។ អ្នកខ្លះបានយល់ច្រឡំថា ព្រះយេស៊ូវគ្រាន់តែជាបុរសល្អម្នាក់ ហើយបង្រៀនមនុស្សពីរបៀបរស់នៅឲ្យបានល្អប្រសើរ។ ហើយអ្នកខ្លះទៀតគិតថា ព្រះយេស៊ូវទ្រង់យាងមក ដើម្បីដាក់ទោសមនុស្ស ចំពោះអំពើបាបរបស់ពួកគេ។ ប៉ុន្តែយើងពឹងលើអ្វីដែលគម្ពីរបានបង្រៀនយើង។ ព្រះគម្ពីរប្រាប់យើងថា ព្រះស្រឡាញ់យើងខ្លាំងណាស់ ទ្រង់បានចាត់ព្រះរាជបុត្រារបស់ទ្រង់មក ដើម្បីសង្គ្រោះយើងពីអំពើបាបរបស់យើង។

អំពើបាបខ័ណ្ឌយើងជាមួយនឹងព្រះ។ បើយើងមិនបានសង្គ្រោះទេ យើងមិនអាចរស់នៅជាមួយនឹងព្រះបានឡើយ។

ព្រះគម្ពីរបានប្រាប់យើងថា មុនយើងបានសង្គ្រោះ យើងបានស្លាប់ក្នុងអំពើបាបរបស់យើងហើយ។ យើងគ្មានសង្ឃឹមទេ ពីព្រោះពេលយើងធ្វើបាប ទោសរបស់យើងនោះគឺសេចក្តីស្លាប់។ លោកីយ៍នេះខ្មៅងងឹតមុនពេលដែលព្រះយេស៊ូវយាងមក។ ព្រះគម្ពីរបានប្រាប់យើងថា ព្រះយេស៊ូវគឺជាពន្លឺ។ ប៉ុន្តែ បើទោះបីជា ពេលព្រះយេស៊ូវដែលជាពន្លឺ យាងចូលមកក្នុងលោកីយ៍ក៏ដោយ ក៏មនុស្សជាច្រើននៅតែចូលចិត្តភាពងងឹតជាង។ មនុស្សចូលចិត្តភាពងងឹត ព្រោះវាងាយស្រួលក្នុងការលាក់បាំងអំពើបាប របស់ពួកគេនៅក្នុងទីងងឹត។ ដូច្នេះ តើយើងអាចបំបាត់អំពើបាបទាំងអស់របស់យើងដោយរបៀបណា? តើយើងអាចបញ្ឈប់អំពើបាបដោយរបៀបណា? តើយើងត្រូវធ្វើដូច្នេះដើម្បីបានសង្គ្រោះ?

ព្រះគម្ពីរមានដំណឹងល្អសម្រាប់យើង។ វាជារឿងសំខាន់ក្នុងការយល់ថា គ្មានអ្វីដែលយើងអាចធ្វើបានដើម្បីរកបានសេចក្តីសង្គ្រោះនោះទេ។ យើងមិនអាចទទួលបានសេចក្តីសង្គ្រោះ ដោយការធ្វើតាមគ្រប់ច្បាប់នោះទេ។ យើងមិនអាចទទួលបានសេចក្តីសង្គ្រោះ ដោយការទទួលបានចំណាត់ថ្នាក់ល្អនោះទេ។ យើងមិនអាចទទួលបានសេចក្តីសង្គ្រោះ ដោយការធ្វើជាមិត្តដ៏ល្អនោះទេ។ យើងទាំងអស់គ្នាត្រូវការសេចក្តីសង្គ្រោះពីព្រះ ប៉ុន្តែវាមិនមែនជាអ្វីដែលយើងអាចធ្វើបាន ក្នុងការទទួលបានការសង្គ្រោះនោះទេ។

សេចក្តីសង្គ្រោះគឺជាអំណោយមកពីព្រះ។ ព្រះគម្ពីរចែងថា ពេលយើងឮព្រះបន្ទូលរបស់ព្រះយេស៊ូវ ហើយជឿលើទ្រង់ នោះទ្រង់នឹងប្រទានជីវិតអស់កល្បជានិច្ចដល់យើង។ ពេលយើងមានជីវិតអស់កល្បជានិច្ចយើងឆ្លងផុតពីសេចក្តីស្លាប់ - ភាពងងឹត - ទៅកាន់ជីវិតក្នុងពន្លឺ។ ដោយសារសេចក្តីសង្គ្រោះរបស់ព្រះយើងអាចរស់នៅជារៀងរហូតជាមួយនឹងទ្រង់។ អ្វីដែលព្រះបានសុំគឺថា យើងទុកចិត្តនិងជឿលើព្រះយេស៊ូវ ដែលបានសុគតនៅលើឈើឆ្កាងសម្រាប់អំពើ បាបរបស់យើង។ ព្រះបានបញ្ជូនព្រះយេស៊ូវមកផែនដីដើម្បីជួយយើង ឲ្យស្វែងយល់អំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ អំពើបាបខ័ណ្ឌយើងជាមួយនឹងព្រះ។ ឈ្នួលនៃអំពើបាបគឺជាសេចក្តីស្លាប់ ហើយព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងដើម្បីអំពើបាបរបស់យើង។ ព្រះជាម្ចាស់សង្គ្រោះយើង ដោយសារ ទ្រង់ស្រឡាញ់យើងខ្លាំងណាស់!

## ៦. សំនួរពិភាក្សា

១. តើអ្វីដែលខ័ណ្ឌយើងជាមួយនឹងព្រះ? *(អំពើបាប)*

២. ហេតុអ្វីបានជាព្រះបញ្ជូនព្រះរាជបុត្រាឲ្យមក? *(ដើម្បីសង្គ្រោះយើងពីអំពើបាប)*

៣. តើយើងត្រូវធ្វើអ្វីដើម្បីទទួលបានការសង្គ្រោះ? *(ជឿលើព្រះដែលបានចាត់ព្រះយេស៊ូវឱ្យ មកសុគត ជំនួសអំពើបាបរបស់យើង ដើម្បីយើងអាចទទួលបានសេចក្តីសង្គ្រោះ)*
៤. ហេតុអ្វីបានជាព្រះសង្គ្រោះពួកយើង? *(ព្រោះព្រះអង្គស្រលាញ់យើងខ្លាំងណាស់!)*

## ៧. ល្បែងកំសាន្ត «តើអ្នកអាចសង្គ្រោះខ្លួនឯងបានដែរឬទេ?»

សម្ភារៈដែលត្រូវការ៖ ចានពីរ ស្លាបព្រា ដបទឹកសុទ្ធទទេ ( ហើយចោះរន្ធតូចៗនៅផ្នែកខាងក្រោមនៃដប)



១. ដាក់ដបទឹកទទេនៅខាងក្នុងចានមួយ។ ដើម្បីការពារទឹកមិនឲ្យលេច នៅលើឥដ្ឋ។ ហើយដាក់វានៅផ្នែកម្ខាងទៀតនៃថ្នាក់រៀន។
២. ចែកកុមារជាពីរក្រុមហើយឲ្យស្លាបព្រាទៅក្រុមទាំងពីរ។
៣.ក្រុមនីមួយៗត្រូវព្យាយាមដួសទឹក ដោយប្រើស្លាបព្រារបស់ពួកគេ ហើយរត់យកទឹកនោះទៅដាក់បំពេញនៅក្នុងដប។ ក្រុមណាដែលអាច ដាក់ទឹកបានពេញដបមុនគេក្រុមនោះជាអ្នកឈ្នះ។
៤. សូមទុកពេលឲ្យកុមារក្នុងការលេងល្បែងនេះតែ ៣នាទីបានហើយ។
៥. បន្ទាប់ពី ៣នាទីក្រោយមក សូមលើកដបឡើង ហើយឱ្យកុមារមើល ថាដបទាំងពីរគ្មានទឹកទេ (ព្រោះទឹកហូរតាមរន្ធអស់ហើយ)។
៦. សូមពន្យល់កុមារថា ការព្យាយាមស្វែងរកសេចក្តីសង្គ្រោះរបស់យើងពីព្រះ គឺដូចជាការបំពេញទឹកដាក់ដប ដែលមានរន្ធធ្លុះអីចឹង។ វាជាកិច្ចការដែលមិនអាចទៅរួច! យើងមិនអាចសង្គ្រោះខ្លួនឯងបានទេ។ មានតែព្រះទេដែលអាចសង្គ្រោះយើងបាន តាមរយៈការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង។ ជឿលើព្រះយេស៊ូវនោះ អ្នកនឹងបានសង្គ្រោះ!

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ៣៖១៧** *"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ"។*

## ៩. ហត្ថកម្ម « ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះខ្ញុំ»

សម្ភារៈដែលត្រូវការ៖ បន្ទះឈើ កាវ ក្រដាស ប៊ិច



១. បង្កើតរូបឈើឆ្កាងពីបន្ទះឈើ ដោយប្រើកាវបិត។
២. កុមារអាចតុបតែងរូបឈើឆ្កាង បាន ប្រសិនបើពួកគេចង់។
៣.សរសេរប្រយោគ " ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះខ្ញុំ" នៅលើក្រដាសហើយបិតវានៅលើឈើឆ្កាង។




៤. សូមរំលឹកកុមារថា ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះពួកគេ ពីព្រោះពួកយើងមិនអាចសង្គ្រោះខ្លួនឯងបាននោះទេ។ អរព្រះគុណព្រះជាម្ចាស់ដែលបានជួយសង្គ្រោះពួកយើង!

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ការមានទំនាក់ទំនងជាមួយព្រះយេស៊ូវបានផ្តល់នូវគុណសម្បត្តិដ៏អស្ចារ្យជាច្រើន ប៉ុន្តែគុណសម្បត្តិដ៏វិសេសជាងគេនោះគឺ៖ យើងរាល់គ្នានឹងត្រូវបានសង្គ្រោះ ហើយកើតជាថ្មី! ធ្វើឱ្យយើងទទួលបាននូវជីវិតថ្មី មានការចាប់ផ្តើមជាថ្មី!
ខគម្ពីរចងចាំថ្ងៃនេះចែងថា ព្រះយេស៊ូវមិនបានយាងមកដើម្បីថ្កោលទោសពិភពលោកទេ ប៉ុន្តែដើម្បីសង្គ្រោះពិភពលោកវិញ។ ក្នុងនាមជាមនុស្សដែលបានសង្គ្រោះ យើងត្រូវការរស់នៅក្នុងជីវិតដែលខុសពីលោកីយ៍នេះ។ សូមអធិស្ឋាន ហើយទូលសុំឱ្យព្រះជួយអ្នកឱ្យប្រព្រឹត្តខុសពីលោកីយ៍នេះ នៅពេលអ្នកបន្តស្រឡាញ់ព្រះ និងស្រឡាញ់មនុស្ស។